

# អាប់ឌុល ខាឡាម : មេរៀនចំពោះ គ្រូរបស់ខ្ញុំ

Let's Read

The Asia Foundation

អ្នកនិពន្ធ វិចិត្រករ និងអ្នកបោះពុម្ពសៀវភៅលើកទឹកចិត្ត និងគាំទ្រការបកប្រែសៀវភៅនេះទៅជាភាសាផ្សេងៗ ប៉ុន្តែពួកគេស្នើសុំឲ្យការផ្លាស់ប្តូរខ្លឹមសារ និងរូបគំនូរស្ថិតក្នុងកម្រិតតិចតួចបំផុត។



ខ្ញុំរស់នៅលើផ្លូវដែលមានវិហារអីុស្លាមក្នុងទីក្រុងរ៉េមស្វារុំ ដែលជាទីក្រុងដ៏ល្បីល្បាញមួយ ដោយសារតែវត្តរបស់ព្រះសិវៈនៅទីនោះ។ រាល់ល្ងាចនៅពេលដែលខ្ញុំចេញពីវិហារដើរទៅផ្ទះ ខ្ញុំតែងតែសំងំនៅជិតវត្តនោះ។



ខ្ញុំតែងមានអារម្មណ៍ថា ខ្លួនឯងដូចជាមនុស្សចម្លែកនៅទីនោះ ពីព្រោះអ្នកទៅវត្តទាំងឡាយតែងតែមើលមកខ្ញុំដោយប្រើក្រសែភ្នែកដ៏សង្ស័យ។ ពួកគាត់ប្រហែលជាឆ្ងល់ថា ក្មេងប្រុសអ៊ីស្លាមម្នាក់នេះកំពុងធ្វើអ្វីនៅមុខវត្ត។




ការពិត ខ្ញុំចូលចិត្តស្ដាប់សម្លេងសូត្រធម៌នោះ ទោះជាខ្ញុំមិន
យល់សូម្បីតែមួយពាក្យក៏ដោយ។ វាមានវេទមន្តចម្លែកនៅក្នុង
ធម៌នោះ។



ប្រាកដណាស់ថា មានអ្វីម្យ៉ាងនាំខ្ញុំទៅទីនោះ។ មិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំឈ្មោះ រ៉ាម៉ាណាដា សាសទ្រី ជាកូនប្រុសរបស់មេបព្វជិតនៅទីនោះ។ គេតែងអង្គុយក្បែរឪពុករបស់គេ នៅពេលសូត្រធម៌។ រ៉ាម៉ា តែងលួចញញឹមដាក់ខ្ញុំម្តងម្កាល។



នៅក្នុងថ្នាក់រៀន រ៉ាម៉ា និងខ្ញុំអង្គុយជាមួយគ្នានៅតុទីមួយ។ ពួកយើងដូចបងប្អូនអ៊ីចឹង...។ ប៉ុន្តែដោយសារគេជាកូនប្រុសរបស់បព្វជិត គេពាក់ខ្សែសីមា ។រីឯខ្ញុំពាក់មួកពណ៌សដែលបង្ហាញថាខ្ញុំជាជនជាតិអ៊ីស្លាម។



ថ្ងៃមួយ នៅពេលរៀនថ្នាក់ទីប្រាំ លោកគ្រូថ្មីម្នាក់បានចូលមក ក្នុងថ្នាក់រៀនរបស់ពួកយើង។ គាត់ដូចជាតឹងរឹងណាស់។ គាត់ដើរជុំវិញថ្នាក់ទាំងកាន់រំពាត់ក្នុងដៃ ហើយក៏ឈប់នៅមុខពួកយើង។



គាត់ស្រែកថា៖ ”ប្អូនដែលពាក់មួកពណ៌ស។ ហេតុអ្វីបានជាហ៊ានអង្គុយនៅក្បែរកូនរបស់បព្វជិត? ទៅអង្គុយនៅតុក្រោយបង្អស់ភ្លាម”។ ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់។ ខ្ញុំយកសៀវភៅ ហើយដើរទៅអង្គុយនៅតុក្រោយបង្អស់ទាំងទឹកភ្នែក។



រ៉ាម៉ា និង ខ្ញុំ យំខ្សឹកខ្សួល ពេលចេញពីសាលា។ ពួកយើង
ប្រហែលជាមិនអាចក្លាយជាមិត្តនឹងគ្នាទៀតទេ។



នៅពេលទៅដល់ផ្ទះ ឪពុករបស់ខ្ញុំបានមើលមកខ្ញុំ ហើយសួរថា៖ ”តើកូនបានយំមែនឬទេ? តើមានអ្វីកើតឡើងកូន?” ខ្ញុំបានប្រាប់គាត់ពីអ្វីដែលបានកើតឡើង រីឯ រ៉ាម៉ា ក៏បានប្រាប់គ្រួសាររបស់គាត់នូវរឿងនេះដូចគ្នា។



នៅពេលព្រឹកព្រលឹម រ៉ាម៉ា បានរត់មកផ្ទះខ្ញុំ ហើយនិយាយថា ៖ ”ប៉ារបស់ខ្ញុំឲ្យហៅឯងទៅផ្ទះពួកយើង”។ ខ្ញុំភ័យណាស់។ ខ្ញុំគិតថា ប្រហែលមានរឿងអ្វីទៀតហើយ។



ពួកយើងក៏បានប្រញាប់ទៅផ្ទះរបស់ រ៉ាម៉ា។ បេះដូងរបស់ខ្ញុំលោតខុសចង្វាក់នៅពេលដែលខ្ញុំបានឃើញលោកគ្រូថ្មីឈរនៅទីនោះ។



ប៉ារបស់ រ៉ាម៉ា បាននិយាយទាំងទឹកមុខយ៉ាងមាំថា៖ ”លោកឆាប់សុំទោស ខាឡាម ទៅ”។ ខ្ញុំមិនចង់ជឿអ្វីដែលខ្ញុំបានឮទេ! មេបព្វជិតបានឲ្យលោកគ្រូសុំទោសខ្ញុំឬ?



ប៉ារបស់ រ៉ាម៉ា បាននិយាយថា៖ ”គ្មានក្មេងណាមានឋានៈទាបជាងក្មេងណាទេ ក្នុងក្រសែភ្នែករបស់ព្រះ។ វាជាភារកិច្ចរបស់គ្រូបង្រៀនក្នុងការជួយសិស្សឲ្យរស់នៅដោយសុខដុមរមនា ទោះជាគេមានប្រវត្តិបែបណាក៏ដោយ។ អ្នកមិនអាចបង្រៀននៅសាលានេះបានទៀតទេ។”



ភ្លាមនោះ លោកគ្រូបានសុំឲ្យខ្ញុំអភ័យទោសឲ្យគាត់។ គាត់បានឱបខ្ញុំ ហើយនិយាយថា៖ ”លោកគ្រូសុំទោស ខាឡាម។ ថ្ងៃនេះគ្រូបានយល់អំពីមេរៀនជីវិតដ៏សំខាន់មួយ។”



ប៉ារបស់ រ៉ាម៉ា ឃើញថាលោកគ្រូបានសោកស្ដាយចំពោះទង្វើរបស់គាត់ ហើយបានអនុញ្ញាតឲ្យគាត់បន្តបង្រៀនទៀត។



ចាប់ពីថ្ងៃនោះមក រ៉ាម៉ា និងខ្ញុំអង្គុយជាមួយគ្នានៅតុមុខយ៉ាង
មានមោទនភាព។ ពួកយើងនៅតែជាមិត្តល្អនឹងគ្នាជារៀង
រហូត។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Abdul Kalam: A Lesson for My Teacher*, Published by BookBox, © BookBox. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Jimmy M and Kem Lyheang